ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១១

លេខ ០១ កយ.សសរ/១១

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌

## រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦ ក្រ. ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១០/០០១ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ៤៥ កយ.ប្រក/០៨ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅថ្នាក់ការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គនាយកដ្ឋាននានារបស់ក្រសួងយុត្តិធម៌

- យោងតាមការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតអាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌ ស្ថិតនៅក្រោមយុត្តាធិការនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ ដើម្បីជួយសម្របសម្រួលលើការងារជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម បត្យាប័ន និងការបញ្ជូនទណ្ឌិត ។

**ប្រការ ២ :** អាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌ មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម ផូវ សំភី | អគ្គនាយកស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យុត្តិធម៌ | ប្រធាន |
| ២- លោក គី ខេមលីន | អគ្គនាយករងស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យុត្តិធម៌ | អនុប្រធាន |
| ៣- លោក ប៊ុន ប៉ៃណារិន | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- លោក ច័ន្ទ សត្ថា | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | សមាជិកអចិន្ត្រៃយ៍ |
| ៥- លោក ពៅ ប៊ុនធឿន | ប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ | សមាជិក |
| ៦- លោក ទូច ថារិទ្ធ | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី | សមាជិក |
| ៧- លោក ស៊ឹង សារ៉ាត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | សមាជិកអចិន្ត្រៃយ៍ |
| ៨- លោក មៅ គុយលីម | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | សមាជិកអចិន្ត្រៃយ៍ |
| ៩-លោកស្រី សៀង សុខណា | ប្រធានការិយាល័យកិច្ចការបរទេស | សមាជិក |
| ១០- លោក ង៉ែត ដាវុធ | ប្រធានការិយាល័យកិច្ចការអាស៊ាន | សមាជិកអចិន្ត្រៃយ៍ |
| ១១- លោក ឌិ ពេជ្រវាសនា | អនុប្រធានការិយាល័យកិច្ចការអាស៊ាន | សមាជិក |
| ១២- លោកស្រី ផល សុភាព | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ១៣- លោក ពៅ វិបុល | មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | សមាជិក |

**ប្រការ ៣ :** អាជ្ញាធរកណ្តាលមានបេសកកម្ម តួនាទី និងភារកិច្ចដូចតទៅ :

១- ទទួលពិនិត្យ និងសម្របសម្រួលលើសំណើ នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម បត្យាប័ន និងការបញ្ជូនទណ្ឌិត

២- បញ្ជូនសំណើទៅភ្នាក់ងារពាក់ព័ន្ធ និងបញ្ជូនសំណើត្រឡប់ទៅភាគីម្ចាស់សំណើ

៣- រៀបចំបញ្ចូលព័ត៌មាន និងតាមដានរាល់សំណើដែលបានទទួល និងបញ្ជូន ដើម្បីធានាឱ្យមានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងឱ្យបានឆាប់រហ័ស

៤- ដើរតួរជាអង្គភាពបង្គោល ដើម្បីសម្របសម្រួលរាល់បញ្ហាទាក់ទងនឹងជំនួយផ្នែកច្បាប់

៥- ធ្វើការទំនាក់ទំនងដោយផ្ទាល់ ឬតាមរយៈផ្លូវទូត ជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីសម្របសម្រួលលើការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់

៦- រៀបចំពិនិត្យ និងសម្របសម្រួលការបកប្រែភាសាលើសំណើសុំ ឯកសារសំណុំរឿង ភស្តុតាង និងឯកសារពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់

៧- រៀបចំទិន្នន័យនៃសំណើសុំជំនួយផ្នែកច្បាប់ និងចងក្រងឯកសារច្បាប់ដោយបញ្ចូលទៅក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យ ដោយបង្ហោះនៅលើគេហទំព័ររបស់ក្រសួងយុត្តិធម៌

៨- រក្សាការសំងាត់ចំពោះសំណើសុំជំនួយ ខ្លឹមសារ និងឯកសារគាំទ្រសំណើ ហេតុការណ៍នៃការផ្តល់ជំនួយ និងចំណាត់ការណាមួយដែលអនុវត្តទៅតាមសំណើ

៩- ធានានូវព័ត៌មាន និងភស្តុតាងត្រូវបានការពារមិនឱ្យបាត់បង់ និងការទទួលបានការប្រើប្រាស់ ការកែប្រែ ការបង្ហាញដោយគ្មានការអនុញ្ញាត ឬការប្រើប្រាស់មិនត្រឹមត្រូវផ្សេងៗ

១០- រៀបចំផែនការសកម្មភាព នៃការអភិវឌ្ឍន៍លើការងារសម្របសម្រួល ការចំណាយ ដំណើរទស្សនកិច្ចសិក្សា ចូលរួមសិក្ខាសាលា និងកិច្ចប្រជុំ ទាំងក្នុង និងក្រៅប្រទេស

១១- ធ្វើការទំនាក់ទំនងជាដៃគូរអភិវឌ្ឍន៍ ដើម្បីស្វែងរកជំនួយក្នុងការបណ្តុះបណ្តាលធនធានមនុស្ស

១២- បង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីសម្របសម្រួលលើការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់

១៣- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ០៩ ខែ និងប្រចាំឆ្នាំ

១៤- ទទួល និងអនុវត្តភារកិច្ចចាំបាច់ផ្សេងៗទៀត តាមការប្រគល់ជូនរបស់ **ឯកឧត្តមរដ្ឋមន្ត្រី** ។

**ប្រការ ៤ :** គ្រប់អង្គភាពក្រោមឱវាទក្រសួង សាលាដំរះក្តី និងអយ្យការគ្រប់ជាន់ថ្នាក់ ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ

រដ្ឋមន្ត្រី

អង្គ-វង្សវឌ្ឍនា

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមហាផ្ទៃ
- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ